# សុភាសិតខ្មែរ



“ចេះមកពីរៀន មានមកពីរក”

“ប្រហែសបាត់ ប្រយ័ត្នគង់”

“ស្រលាញ់ខ្លួនអោយស្ងួនចំណី”

“ទឹកត្រជាក់ត្រីកុម”

“រនាបបាក់អាចយករនាបជួស សំដីជ្រុលជ្រួសជួសមិនបានឡើយ”

“ពាក្យត្រូវវែងរឹង ស្រាវែងស្រវឹង ពុំដែលពិសា ពាក្យពិតវែងស្លែង
ពុំពិរោះថា បណ្ឌិតមេធា វែងថាពុំគាប់” *ព្រះរាជសម្ភារ*

“មានះបាត់មិត្ត ខឹងបាត់ប្រាជ្ញា លេញលេងដៀលថា បាត់ឥរិយាគាប់”
*ព្រះរាជសម្ភារ*

“ទៀងមិនឈ្នះទ័ល”

“ខ្លាវែងស្អប់ចេះ ខ្យត់ឥតចំណេះ ស្អប់អ្នកមានទ្រព្យ ស្រីស្រាលប្រច័ណ្ឌ
វែងស្អប់ខ្ញុំគាប់ ពាលពិតឥតច្បាប់ វែងស្អប់ប្រដៅ” *ព្រះរាជសម្ភារ*

“ខ្លែងហើរដ្បិតខ្យល់ នាយថ្កើងដ្បិតពល រក្សាអោយសុខ
ទ្រព្យគង់ដ្បិតស្រី ចេះសំចៃទុក ផ្ទះធំស្រណុក ដ្បិតភរិយាជា”
*ព្រះរាជសម្ភារ*

“ពាក្យចាស់ពាក្យពីព្រេង ទោសខ្លួនឯងមើលពុំយល់
ទោសគេតូចសោតសល់ រមើលយល់ប៉ុនទាំងភ្នំ
ចូលព្រៃសត្វសាហាវ រកអំពាវគ្នាមកជុំ ដល់បានស្ករទឹកឃ្មុំ
ពួនក្នុងផ្ទះស៊ីម្នាក់ឯង” *ព្រះភិរម្យភាសាអ៊ូ*

“បង់បោយអោយមើលស្រមោលប្រាណ
ដាំដើងក្រានអោយប្រមាណឆ្នាំង”

“បើមិនជួយចូកជួយចែវទេ កុំយកជើងរាទឹក”

“កុំដេញឆ្កែអោយទល់ច្រក”

“ឆ្កែព្រុសមិនដែលខាំ”

“ខ្លួនតូចកុំតោង ដៃខ្លីកុំឈោងស្រវាអោបភ្នំ”

“តូចមែនពិតតែដូចពេជ្រពណ្ណរាយ”

“ចំណេះជាអាហារ ប្រាជ្ញាជាអាវុធ”

“ស្គាល់មិត្តនៅគ្រាក្រ សម្បុរល្អនៅខែកក្តិក”

“ជាងមិនកើតបន្ទោសដែក”

“គ្នាតិចអន្សមខ្លោច គ្នាដូចស្រមោចអន្សមឆៅ”

“ក្អែកមួយជាក្អែកដប់”

“និយាយយប់ផ្ទប់ព្រៃ និយាយថ្ងៃព្រៃមានត្រចៀក”

“រោគអ្វីពុំស្មើនឹងគម្លាន គ្មានអ្វីពុំស្មើគ្មានប្រាជ្ញា
ចាប់អ្វីពុំស្មើចាប់ទោសា ជាអ្វីពុំស្មើនឹងចិត្តជា”

“ក្រោយពេលភ្លៀង មេឃគង់ស្រលះ”

“សូវចង្អៀតផ្ទះ កុំអោយតែចង្អៀតចិត្ត”

“កុំចោលសាច់ស្រវាឆ្អឹង កុំចាក់អង្ករយកអង្កាម”

“ដូងមួយធ្លាយ មិនលែងអីមានតក់មាននាឡិ”

“ត្រីមួយត្រក ស្អុយមួយស្អុយទាំងអស់”

“លួចគេវាគ្រាន់ គេទាន់វាក្រែល”

“លួចគេវាធ្លាប់ដៃ ដេកថ្ងៃវាធ្លាប់ភ្នែក”

“ជិះក្របីចំលងភក់ ស្រណុកជាជាងដើរ”

“ដំរីជើងបួនគង់មានភ្លាត់ អ្នកប្រាជ្ញចេះស្ទាត់គង់មានភ្លេច”

“ឈើកោងធ្វើកង់ ឈើត្រង់ធ្វើកាំ”

“ឈើកោងវល្លិ៍ព័ទ្ធ មនុស្សខ្វាត់ព្រាត់កុំយកខ្លួនបៀត”

“ដល់ពេលក្របីបាត់ទើបធ្វើរបង ដល់ពេលប្រលងទើបស្វាធ្យាយ
ដល់ពេលចេញដើរទើបវេចសំពាយ បីនេះអន្តរាយជាក់ប្រាកដ”

“ដល់កំពង់ កុំអោយលង់ទូក”

“ដំដែកទាន់នៅក្តៅ ប្រដៅមនុស្សទាន់នៅក្មេង”

“ដូចគេរកអុស ប្រទះឈើងាប់”

“អ្នកមានរក្សាខ្សត់ ដូចសំពត់ព័ទ្ធពីក្រៅ អ្នកប្រាជ្ញរក្សាខ្លៅ
ដូចសំពៅនូវសំប៉ាន”

“គុណមួយរយសំពៅ ទោសមួយចូលទៅ រលាយគុណអស់”

“អ្នកខ្ពស់រក្សាទាប ដោយសភាពធម៌បុរាណ អ្នកឆ្អែតរក្សាឃ្លាន នាអ្នករុងរក្សាឆ្អារ”

“នឹងស៊ីកុំតាមឃ្លាន គិតប្រមាណអស់គ្នីគ្នា”

“កុំបាចអង្កាមបញ្ច្រាសខ្យល់”

“កាន់កពស់អោយខ្ជាប់ ខ្លាចក្រលាប់ខាំឯប្រាណ”

“អណ្តាតជាអាទឹកន្លង ស្លាប់ផងរស់ផងក៏ព្រោះអណ្តាត”

“ចេះឯងអោយក្រែងចេះគេ”

“ទូង១ ប្រហោងក្នុងដូចស្គរ”

“ព្រូធ្លលាន់ កុំចាក់ទឹកចោល”

“ហុតទឹកសំលឹងកាក ទាញច្រវាក្រាកសំលឹងត្រើយ”

“ចាប់នេះចាប់នោះមិនឆ្ពោះត្រង់ណា នាំអោយអាត្មាអសារបង់”

“សូវស្លាប់ទៅជា កុំបង់ធម្មាតវិយាសីលគាប់”

“ដាវមុតទុកតែក្នុងស្រោម វិជ្ជាល្អព្រមនៅតែក្នុងក្បួន
ប្រពន្ធគាប់ចិត្តនៅឆ្ងាយខ្លួន ជួនជាត្រូវការអរអាចិត្ត”

“គេខុស កុំអាលអរ គេសាទរ កុំអាលអួត”

“ទឹកហូរមិនដែលហត់ ពាក្យស្បថកុំអោយជឿ”

“ចង់ឆ្ងាញ់អោយរកអន្លក់ ចង់ស្រណុកអោយនៀយពីក្មេង”

“កុំងើយខ្ពស់ស្មើមេឃ កុំអោនពេកអាប់រាសី”

“បំណាច់នឹងចេះ អោយគេកោត បំណាច់នឹងឆោត
អោយគេអាណិត”

“នាងរត់រកអ្នក មេខាតលក្ខណ៍រត់រកអាកំបាក់ទន្សារ”

“សំណាបយោងដី ស្រីយោងប្រុស”

“ចំណីឆ្ងាញ់កុំទុកស្អែក ប្រពន្ធល្អប្លែកកុំអោយដើរក្រោយ”

“កុំទុកចិត្តមេឃកុំទុកចិត្តផ្កាយ កុំទុកចិត្តប្រពន្ធថាគ្មានសាហាយ
កុំទុកចិត្តម្ដាយថាគ្មានបំណុល”

“នឹងរៀនអោយស្ទាត់ កុំចេះស្ទាក់ស្ទើរ ល្ងីល្ងើឥតបទ បើចេះប្រាកដ
ប្រាក់រត់តាមហៅ”

“ទឹកឡើងត្រីស៊ីស្រមោច ទឹកហោចស្រមោចស៊ីត្រី”

“ដល់កំពង់សឹមតោង”

“ឃ្លានឆ្ងាញ់ ស្រលាញ់ល្អ”

“កុំប្រឹងជុះតាមដំរី”

“មនុស្សគេយកសំដី ដំរីគេយកភ្លុក”

“ដំរីស្លាប់កុំយកចង្អេរមកបាំង”

“ពងមាន់កុំជល់នឹងថ្ម”

“ទំពក់វាទៅ ទើបញ្ចៀវវាមក”

“អន្ទង់វែង កុំរកឆ្នាំងវែង”

“កុំអោយមនុស្សខឹងលាងចាន កុំអោយមនុស្សឃ្លានដាំបាយ”

“អូសទូកកុំអោយល្អាន ចាប់ត្រីបានកុំអោយល្អក់ទឹក”

“ធ្វើស្រែអោយមើលស្មៅ ទុកដាក់កូនចៅអោយមើលផៅសន្តាន”

“ទឹកបាក់ទៅទាប បុណ្យបាត់ជ្បិតបាប”

“កុំដេកចាំសំណាង កុំក្មេងក្មាងចាំបុព្វេ ខំរកកុំទំនេរ
រៀនវិះចេះអោយគ្រប់”

“តក់ៗពេញបំពង់”

“ឃើញឈើពុក កុំដាក់គូទអង្គុយ”

“ស្អប់ជិពប់លើ”

“ប្អូនអើយកុំសើចបង ប្រយ័ត្នពៀរឆ្លងម្តងម្នាក់”

“ចាស់អាងស្លាប់ ពាលអាងកាប់ ក្មេងអាងយំ”

“សន្សឹមកុំបំបោល ក្រែងពុំដល់ដូចប្រាថ្នា ... ប្រើគេប្រើអោយត្រា
កុំសាំសឹនរនចៅរ៉ៅ”

“កោក១ សឹកមាត់ត្រដោក ឆ្អែតពោះក្របី”

“កុំយកពងមាន់ទៅផ្ញើនឹងក្អែក”

“នៅផ្ទះម្តាយទីទៃ ទៅព្រៃម្តាយតែមួយ”

“ចេះដប់មិនស្មើប្រសប់មួយ”

“ស្នេហ៍មិនស្មើស្និទ្ធ”

“ចំណេះជិះកឯង”

“កុំឈ្លោះនឹងស្រី កុំក្ដីនឹងចិន”

“លោកថាកុំឆ្កួតបី ឆ្កួតស្រា ឆ្កួតស្រី ឆ្កួតល្បែងពាលា”

“ផើយស្ទក អោយដាក់គ្រាប់”

“ស្ងូវស្ងៀមជាងស្រដី ទំពាររចេកខ្ចីសោះនឹងនៅមាត់ទំនេរ”

“កុំផើងដោយខ្យល់ កុំខ្វល់ដោយស្រី” ***ព្រះរាជសម្ភារ***

“ស្លឹកឈើជ្រុះមិនឆ្ងាយពីគល់”

“ឃើញខ្លាក្រាបកុំថាខ្លាសំពះ”

“ស្លូតស្លាប់ វៀចវេរមានភ័ព្វអាយុយឺនយូរ”

“ពាក្យមនុស្សវែងជាផ្លូវ”

“កុំស្លាប់ដូចពស់ កុំរស់ដូចកង្កែប”

“កុំបានតែមាត់ ត្រកៀកស្លាប់ស្លូក”

“អ្នកហ៊ានស្បែកជាច អ្នកខ្លាចស្បែកស្វិត”

“កុំយកកងចក្រថាជាផ្កា កុំយកបន្លាថាជាស្បៃ”

“ឃើញគេទៅ កុំអោយខាន ឃើញគេបាន កុំអោយទៅ”

“ងាប់នឹងសំដីដូចត្រីកំភ្លាញ ងាប់នឹងអាចម៍ឯងដូចខ្ញែក”

“រឹនំមិនដែលធំជាងនាឡិ កូនគោកាចកៀចដោយព្រៃវាល
រោលរាលឈឺខ្លួនជូនដល់ក្ស័យ” ***ព្រះភិក្ខុសោម***

“ទ្រព្យច្រើនព្រួយរក្សា ទ្រព្យតិចណាព្រួយរិះរក”

“ឃ្លាតឆ្ងាយ ណាយចិត្ត”

“ទឹកបាក់ទៅទាប បុណ្យបាត់ដ្បិតបាប លាភបាត់ដ្បិតឃោរ
ទឹកថ្លាដ្បិតរលក មិនយល់ស្រមោល ទោសកើតដ្បិតពោល
ល្មមមាត់ឈ្លានពាន” ***ព្រះរាជសម្ភារ***

“ធម្មតាមនុស្សអកតញ្ញូ បើទុកជាលើកផែនដីទាំងមូលអោយ
ក៏នៅមិនលែងរករឿងអ្នកមាន គុណវិញ”

“ផ្ចប់អាបនិងស្នេហ៍ ទាំងនេះសុទ្ធតែ ជាទុព្វិជ្ជា កូនចៅកុំរៀន
របៀនពាលា អ្នករៀនតែងជា មនុស្សនឹកស្តាយក្រោយ”

“គោចាស់ ប្រទះស្មៅខ្ចី”

“កុំទុកចិត្តបរទេស កុំទុកចិត្តអភិនេស្រ្កម៏ កុំទុកចិត្តអភិប្រាយ
ប្រើទំលែងខ្ពស់ សំលឹងអោយឆ្ងាយ ស្តាប់ពាក្យបរិយាយ
បណ្តាំមេដី” ***ព្រះរាជសម្ភារ***

“ភូតនៅហោ ចោរនៅជាង”

“ទឹកហូរតិចៗ មិនលែងអីដាច់ថ្ម”

“ចិត្តជាទេវទត្ត មាត់ជាទេវតា”

“កុំទុំមុនស្រគាល”

“ទំពាំងស្នងឫស្សី កុលបុត្រប្រុសស្រីស្នងជាតិ”

“ចង់ចំណេញ ដាច់ចំណង”

“ចចើងលាភ វែងបាត់ធនទៅ”

“ជួញជិតប្រសើរជាងជួញឆ្ងាយ”

“អ្នកមានទ្រព្យា បើមានចិត្តជា សំបូរមិត្តភក្តិ តែងមកឈូរឆ
កំដរឥតអាក់ នាំអោយត្រជាក់ ចិត្តថ្លើមជានិច្ច”

“សូវស្លាប់បា កុំអោយតែស្លាប់មេ សូវលិចទូកកណ្តាលទន្លេ
កុំអោយតែភ្លើងឆេះផ្ទះ”

“ធ្វើស្រែមើលស្មៅ សន្តានមើលផៅ បំរើមើលពុត
ទោះដឹងពុតជា ពុំចេរពុតត្បុត ដឹងចិត្តបរិសុទ្ធ ពុំចេរឥរិយា ”

***ព្រះរាជសម្ភារ***

“កុំបើកទ្រូងអោយក្អែកចោះ”

“សំដីសជាតិ មារយាទសពូជ”

“ថោកអ្វីនឹងដៃ ថ្លៃអ្វីនឹងមាត់”

“ខ្មាសគ្រូខ្សត់ប្រាជ្ញា ខ្មាសប្រពន្ធខ្សត់កូន”

“សំលឆ្ងាញ់ព្រោះគ្រឿង នគររុងរឿងព្រោះមានអ្នកប្រាជ្ញ”

“កុំខឹងគោ វាយរទេះ”

“បើគ្មានភ្លើង ក៏គ្មានផ្សែងដែរ”

“កុំឆ្អិនក្បាលស៊ីក្បាល ឆ្អិនកន្ទុយស៊ីកន្ទុយ”

"ការពារប្រសើរជាងព្យាបាល"

"គ្រូកាច សិស្សខូច"

"ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ"

"ទូកទៅ កំពង់នៅ"



(រូបភាពពីអ៊ីនធឺណិត)